មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
គោលការណ៍ស្តីពីការគ្រប់គ្រងផ្អែកលើលទ្ធផល

កែសម្រួល៖ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០

គោលការណ៍ស្តីពីការគ្រប់គ្រងផ្អែកលើលទ្ធផល

សេចក្តីផ្តើម

ការគ្រប់គ្រងផ្អែកលើលទ្ធផល គឺជាចំណុចស្នូលនៃសិល្បៈគ្រប់គ្រង និងការអនុវត្តការគ្រប់គ្រងរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(«ម.ស.ម.ក»)។ ការគ្រប់គ្រងផ្អែកលើលទ្ធផលគឺជាវិធីសាស្ត្រគ្រប់គ្រងមួយដែលក្នុងនោះការអនុវត្តសកម្មភាពនិងការប្រើប្រាស់ធនធានគ្រប់យ៉ាង គឺឆ្ពោះទៅរកការសម្រេចបាននូវលទ្ធផល និងផលដៈតាមការកំណត់ និងការចង្អុលបង្ហាញច្បាស់លាស់។

ម.ស.ម.ក ផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើលទ្ធផលនៃការបំពេញការងារ ដើម្បីធានាថាខ្លួនអាចផលិតគុណភាពការងារបានល្អប្រសើរ ស្របទៅនឹងទំហំថវិកាដែលបានចំណាយ ព្រមទាំងប្រើប្រាស់ធនធានមនុស្ស និងហិរញ្ញវត្ថុដោយការប្រុងប្រយ័ត្ន។ ការគ្រប់គ្រងផ្អែកលើលទ្ធផលអនុញ្ញាតឱ្យមានអន្តរាគមន៍នានាដើម្បីបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក និងជៀសវាងការចំណាយត្រួតគ្នា ឬខ្ជះខ្ជាយ។ ប្រការនេះនឹងគាំទ្រដល់ការបង្កើតផែនការហិរញ្ញវត្ថុ កម្មវិធី ផែនការគម្រោង ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃបានល្អ។

គោលការណ៍គ្រប់គ្រងផ្អែកលើលទ្ធផលនេះ (តទៅហៅថា "គោលការណ៍") បង្កើតឡើងដើម្បីគូសបញ្ជាក់ឡើងវិញពីសារៈសំខាន់នៃការគ្រប់គ្រងផ្អែកលើលទ្ធផលដែលជាមូលដ្ឋានសម្រាប់ ម.ស.ម.ក វាយតម្លៃ និងជួយបុគ្គលិក ម.ស.ម.ក ឱ្យបានយល់ដឹងអំពីវាក្យសព្ទដែលប្រើនៅ ម.ស.ម.ក ។ គោលការណ៍នេះសម្រាប់អនុវត្តចំពោះបុគ្គលិកគ្រប់រូបរបស់ ម.ស.ម.ក ដូចមានកំណត់ក្នុងគោលការណ៍ស្តីពីការងារក្នុងនោះរួមទាំងទីប្រឹក្សា អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្ត។

១. ការអនុវត្ត

ម.ស.ម.ក នឹងផ្តល់បរិយាកាសការងារដែលផ្តល់តម្លៃលើការគ្រប់គ្រងផ្អែកលើលទ្ធផល។ ការគ្រប់គ្រងផ្អែកលើលទ្ធផលទាមទារឱ្យមានការរៀបចំផែនការល្អ ការត្រួតពិនិត្យ និងការវាយតម្លៃ ហើយទាំងនេះគឺជាចំណុចសំខាន់នៅក្នុងការអនុវត្តការងាររបស់ ម.ស.ម.ក។

១.១. សមាសធាតុសំខាន់នៃការគ្រប់គ្រងផ្អែកលើលទ្ធផលរបស់ ម.ស.ម.ក

ចំណុចសំខាន់ចំពោះការគ្រប់គ្រងផ្អែកលើលទ្ធផល គឺគោលការណ៍ទាំងឡាយដែលផ្តោតយកចិត្តទុកដាក់ទៅលើការប្រែប្រួលរបស់ក្រុមគោលដៅ ការរៀនសូត្រពីលទ្ធផលតាមរយៈការអនុវត្តគម្រោង និងបន្ទាប់មកគឺការសម្របការអនុវត្តការងារទៅតាមកាលៈទេសៈចាំបាច់។ ដើម្បីអនុវត្តតាមគោលការណ៍ទាំងនេះ ម.ស.ម.ក ផ្តោតលើសមាសធាតុសំខាន់ៗចំនួនបួននៃគោលការណ៍គ្រប់គ្រងផ្អែកលើលទ្ធផល។

- **ការកំណត់លើលទ្ធផលដែលបានរំពឹងទុក៖** លទ្ធផលដែលចង់សម្រេចបាននឹងមានលើកឡើងយ៉ាងច្បាស់នៅក្នុងផែនការយុទ្ធសាស្ត្រទូទៅឬផែនការគម្រោងនីមួយៗរបស់ ម.ស.ម.ក។

- **ប្រព័ន្ធវាយតម្លៃលទ្ធផល៖** ក្នុងករណីអាចទៅរួច ម.ស.ម.ក នឹងធ្វើការវាយតម្លៃនៅពេលចាប់ផ្តើមគម្រោងនីមួយៗដើម្បីបង្កើតចំណុចចាប់ផ្តើមរបស់គម្រោង ដែលនឹងបង្កើតបានជាខ្នាតសម្រាប់ការវាយតម្លៃពីវឌ្ឍនភាពនាពេលអនាគត។ ម.ស.ម.ក នឹងតាមដាននិងវាយតម្លៃលទ្ធផលជាបន្តបន្ទាប់ឱ្យស្របតាមដំណើរការត្រួតពិនិត្យ និងវាយតម្លៃនៅក្នុងស្ថាប័ន ដូចជា ផែនការការងារគម្រោងនិងឧបករណ៍តាមដាននានាជាដើម។
- **ការកំណត់ និងការគ្រប់គ្រងជំសកម្មលើហានិភ័យចំពោះគម្រោង៖** ម.ស.ម.ក នឹងកំណត់ វិភាគនិងវាយតម្លៃហានិភ័យដែលអាចមានផលប៉ះពាល់ជាក់ស្តែងលើលទ្ធផលចង់សម្រេចបានផ្អែកលើសំណើគម្រោង ដែលនឹងត្រូវពិនិត្យឡើងវិញនៅក្នុងការអនុវត្តគម្រោងទាំងមូល។ ម.ស.ម.ក នឹងបង្កើតផែនការគ្រប់គ្រងហានិភ័យដើម្បីកាត់បន្ថយផលប៉ះពាល់នៃហានិភ័យទាំងនេះ។
- **ដំណើរការនៃការពិនិត្យឡើងវិញនិងការបន្សាំ៖** ម.ស.ម.ក នឹងត្រួតពិនិត្យលទ្ធផលជាក់ស្តែងជាទៀងទាត់ដោយធ្វើការប្រៀបធៀបនឹងលទ្ធផលរំពឹងទុក និងសម្របការអនុវត្តគម្រោងក្នុងករណីចាំបាច់។ ម.ស.ម.ក នឹងបញ្ចូលមេរៀន/បទពិសោធន៍ដែលទទួលបានពីការអនុវត្តការងារទៅក្នុងការសម្រេចចិត្តលើការបង្កើតកម្មវិធី។ នៅពេលបញ្ចប់គម្រោង ម.ស.ម.ក នឹងធ្វើការវាយតម្លៃចុងក្រោយដើម្បីបញ្ជាក់ពីសមិទ្ធផលជាក់ស្តែងដែលទទួលបានពីការអនុវត្តគម្រោង។

១.២. ការអនុវត្តជាក់ស្តែង

ម.ស.ម.ក នឹងអនុវត្តការគ្រប់គ្រងផ្អែកលើលទ្ធផលបន្តិចម្តងៗ ដោយធ្វើការកែលម្អវិធីសាស្ត្រមួយចំនួននៅពេលខ្លួនទទួលបានបទពិសោធន៍ពីការអនុវត្តការងារ និងសម្របខ្លួនទៅតាមកាលៈទេសៈជាក់ស្តែង (រួមទាំងការពង្រឹងសមត្ថភាពចាំបាច់ដល់បុគ្គលិក)។ វិធីសាស្ត្រគ្រប់គ្រងផ្អែកលើលទ្ធផលដែលអនុវត្តដោយ ម.ស.ម.ក នេះ នឹងក្លាយជាគោលការណ៍ងាយស្រួលយល់សម្រាប់បុគ្គលិក អ្នកគាំទ្រនិងអ្នកពាក់ព័ន្ធដទៃទៀត។

១.៣. ប្រសិទ្ធភាពក្នុងការអនុវត្តសម្រាប់បុគ្គលិក

ហេតុដូច្នោះ បុគ្គលិកក្នុងគម្រោងនានារបស់ ម.ស.ម.ក ចាំបាច់ត្រូវអនុវត្តដូចតទៅ៖

- **កំណត់**នូវលទ្ធផលដែលគម្រោងរំពឹងទុក ផ្អែកតាមការវិភាគសមស្រប
- **កំណត់ឱ្យបានច្បាស់លាស់អំពីអ្នកទទួលផល និងសកម្មភាពគម្រោងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ**
- **តាមដានការវិវឌ្ឍឆ្ពោះទៅរកការសម្រេចបានលទ្ធផល និងការប្រើប្រាស់ធនធានតាមរយៈការប្រើសូចនាករសមស្រប**
- **កំណត់** និងគ្រប់គ្រងហានិភ័យ ទន្ទឹមនឹងការរឭកដល់លទ្ធផលរំពឹងទុក និងធនធានចាំបាច់នានា

- បង្កើនចំណេះដឹងតាមរយៈការរៀនសូត្រមេរៀននានា និងបញ្ចូលមេរៀនទាំងនោះទៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និង
- រាយការណ៍អំពីលទ្ធផលដែលសម្រេចបាន និងធនធាននានាដែលបានចូលរួម។

១.៤ សេចក្តីណែនាំសម្រាប់បុគ្គលិក

ប្រការដែលសំខាន់នោះគឺធ្វើយ៉ាងណាឱ្យបុគ្គលិក ម.ស.ម.ក យល់ដឹងអំពីសារៈសំខាន់នៃការគ្រប់គ្រងផ្អែកលើលទ្ធផល និងហេតុផលក្នុងការសម្របទៅតាមការគ្រប់គ្រង។ ម.ស.ម.ក នឹងគាំទ្របុគ្គលិករបស់ខ្លួនក្នុងការអនុវត្តគោលការណ៍គ្រប់គ្រងផ្អែកលើលទ្ធផលនេះ តាមរយៈផ្តល់ការបង្ហាញណែនាំ និងការបណ្តុះបណ្តាល ព្រមទាំងធ្វើបច្ចុប្បន្នភាពជាប្រចាំអំពីមូលដ្ឋាននៃមេរៀនដែលទទួលបានពីការអនុវត្តសកម្មភាពការងារ ដោយផ្តោតសំខាន់ទាំងលើគោលការណ៍នានា និងទិដ្ឋភាពជាក់ស្តែងនៃការអនុវត្តគោលការណ៍ការគ្រប់គ្រងផ្អែកលើលទ្ធផល។

២. គណនេយ្យភាព

២.១. គណនេយ្យភាពសម្រាប់ខាងក្រៅ៖

ម.ស.ម.ក នឹងលើកកម្ពស់វប្បធម៌នៃគណនេយ្យភាព និងរាយការណ៍អំពីលទ្ធផលនៃការអនុវត្តសកម្មភាពរបស់ខ្លួនដល់ម្ចាស់ជំនួយ ភាគីពាក់ព័ន្ធ ដៃគូ និងសាធារណជនទូទៅដើម្បីជូនដំណឹងដល់ពួកគេអំពីសមិទ្ធផលដែលខ្លួនសម្រេចបាន។ ការអនុវត្តគោលការណ៍គ្រប់គ្រងផ្អែកលើលទ្ធផលរបស់ ម.ស.ម.ក នឹងផ្តល់នូវចនាសម្ព័នមួយសម្រាប់ការរាយការណ៍អំពីភស្តុតាងនៃលទ្ធផលបំពេញការងារ ដែលនោះនាំឱ្យការធ្វើរបាយការណ៍បង្ហាញលទ្ធផលមានភាពប្រសើរច្បាស់លាស់ជាងមុន។

២.២ គណនេយ្យភាពសម្រាប់ខាងក្នុង៖

ម.ស.ម.ក នឹងបញ្ចូលភស្តុតាងនិងមេរៀនដែលទទួលបានពីការអនុវត្តការងារនាពេលកន្លងមកទៅក្នុងការធ្វើសេចក្តីសម្រេចនៅក្នុងកម្រិតគ្រប់គ្រង ហើយនឹងប្រើប្រាស់សូចនាករវាយតម្លៃលើការបំពេញការងារដើម្បីមានគណនេយ្យភាពផ្នែកគ្រប់គ្រងនៅក្នុងស្ថាប័ន។ ការគ្រប់គ្រងរបស់ ម.ស.ម.ក នឹងមានការចូលរួមជានិច្ចពីបុគ្គលិកក្នុងដំណើរការឆ្លុះបញ្ចាំងធ្វើយ៉ាងណាឱ្យសកម្មភាពនានាអាចចូលរួមចំណែកដល់ការសម្រេចបាននូវលទ្ធផលល្អប្រសើរ។ ម.ស.ម.ក ក៏នឹងធានាថាការគ្រប់គ្រងផ្អែកលើលទ្ធផលនឹងត្រូវបានប្រើប្រាស់ជាព័ត៌មានសំខាន់ក្នុងការវាយតម្លៃលើការបំពេញការងាររបស់បុគ្គលិកផងដែរ។

៣. ភាពជាដៃគូ

ម.ស.ម.ក នឹងបញ្ជ្រាបការគ្រប់គ្រងផ្អែកលើលទ្ធផលឱ្យបានទូលំទូលាយប្រកបដោយប្រសិទ្ធភាពសម្រាប់កិច្ចសហការក្នុងភាពជាដៃគូ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ និងធ្វើការជាមួយដៃគូដើម្បីឱ្យមានការយល់ដឹងទូលំទូលាយអំពីគោលការណ៍នានា និងវាក្យសព្ទនៃការគ្រប់គ្រងផ្អែកលើលទ្ធ

ផល ។ ម.ស.ម.ក នឹងផ្តោតការយកចិត្តទុកដាក់ក្នុងការធានាឱ្យមានការបំពេញបន្ថែម និងផ្តល់អន្តរាគមន៍គាំទ្រគ្នាទៅវិញទៅមកជាមួយដៃគូរបស់ខ្លួន។ ឧទាហរណ៍នៅពេល ម.ស.ម.ក ចូលរួមទទួលខុសត្រូវដើម្បីសម្រេចនូវលទ្ធផលនៅក្នុងកម្រិតគម្រោងជាមួយដៃគូ ហើយ ម.ស.ម.ក ក៏នឹងកំណត់ក្នុងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានាអំពីតួនាទីនិងទំនួលខុសត្រូវរៀងៗខ្លួនរបស់ពួកគេផងដែរ។

៤. និយមន័យសំខាន់

ក) ខ្សែចង្វាក់លទ្ធផល (គំរូសមហេតុផល)៖ ទំនាក់ទំនងដែលបង្កឱ្យមានហេតុនិងផល ឬទំនាក់ទំនង ដែលសមហេតុផល រវាងធាតុចូល សកម្មភាព ទិន្នផល និងលទ្ធផលនៃគោលការណ៍គម្រោង ឬគំនិតផ្តួចផ្តើម។

ខ) ធាតុចូល៖ ធនធានហិរញ្ញវត្ថុ/មនុស្ស សម្ភារៈ និងព័ត៌មាន ត្រូវបានប្រើប្រាស់ដើម្បីផលិតទិន្នផលតាមរយៈសកម្មភាពនានានិងការសម្រេចបានលទ្ធផល។

គ) សកម្មភាព៖ ការអនុវត្តសកម្មភាពនានាតាមរយៈការប្រើប្រាស់ធាតុចូលដើម្បីបង្កើតលទ្ធផល។

ឃ)ទិន្នផល៖ ផលិតផល ឬសេវាកម្មផ្ទាល់ដែលកើតចេញពីសកម្មភាព។

ង) លទ្ធផល៖ ការប្រែប្រួលដែលអាចពិពណ៌នាបាន ឬអាចវាស់វែងបានក្នុងសភាពដែលកើតចេញមកពីទំនាក់ទំនងដែលជាប្រភពបង្កើតឱ្យមានលទ្ធផល។ លទ្ធផលត្រូវបានកំណត់ថាគឺជាផលសម្រេចដែលបំពេញបន្ថែមទៅជាលទ្ធផលរយៈពេលខ្លី មធ្យម ឬរយៈពេលវែង។

ច) លទ្ធផលភ្លាមៗ (រយៈពេលខ្លី)៖ នេះគឺជាការប្រែប្រួលដែលបង្កឡើងដោយផ្ទាល់ពីទិន្នផលរបស់ស្ថាប័នមានដូចជាគោលការណ៍ កម្មវិធី ឬគំនិតផ្តួចផ្តើមជាដើម។ ទាក់ទងនឹងពេលវេលាកំណត់ និងកម្រិតថ្នាក់ទាំងនេះគឺជាលទ្ធផលរយៈពេលខ្លី ហើយជាធម្មតាស្ថិតក្នុងកម្រិតនៃការបង្កើនការយល់ដឹងបន្ថែម ឬការទទួលបានធនធាន ឬការទទួលបានជំនាញក្នុងចំណោមអ្នកទទួលផល។

ឆ) លទ្ធផលកម្រិតមធ្យម (រយៈពេលមធ្យម)៖ ការប្រែប្រួលដែលរំពឹងថានឹងកើតឡើងដ៏សមហេតុផលនៅពេលដែលសម្រេចបានលទ្ធផលមួយ ឬ ច្រើនក្នុងរយៈពេលខ្លី។ ទាក់ទងនឹងពេលវេលានិងកម្រិតទាំងនេះគឺជាលទ្ធផលរយៈពេលមធ្យម ដែលតាមធម្មតាបានសម្រេចនៅចុងបញ្ចប់នៃគម្រោង ហើយជាធម្មតានៅពេលមានការផ្លាស់ប្តូរឥរិយាបទ អាកប្បកិរិយា ឬការអនុវត្តក្នុងចំណោមអ្នកទទួលផល។

ជ) លទ្ធផលរយៈពេលយូរ (រយៈពេលវែង)៖ ការប្រែប្រួលកម្រិតខ្ពស់បំផុតដែលអាចត្រូវបានសន្មត់យ៉ាងសមហេតុផលថាជាគំនិតផ្តួចផ្តើមមួយតាមលក្ខណៈបង្កឱ្យមានលទ្ធផល ហើយនោះគឺជាផលដែលកើតចេញពីលទ្ធផលមួយឬលទ្ធផលច្រើនរយៈពេលមធ្យម។ លទ្ធផលរយៈពេលវែងគឺជាគំនិតផ្តួតផ្តើមប្រកបដោយហេតុផលនិងទទួលយកទម្រង់នៃស្ថានភាពថ្មី ឬការប្រែប្រួលស្ថានភាពអ្នកទទួលផលជានិរន្តរ៍។